# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះពិពណ៌នាពីសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។ នៅត្រីមាសទី១ ឆ្នាំ២០១៥ សេដ្ឋកិច្ចនៅបណ្តាប្រទេសអាស៊ាន មានដំណើរការល្អ លើកលែងតែនៅ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ អត្រាកំណើន ផសស ប្រចាំឆ្នាំ នៅឥណ្ឌូនេស៊ី ធ្លាក់ចុះ ០,៧ឯកតាភាគរយ ហើយនៅម៉ាឡេស៊ី ធ្លាក់ចុះ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ អត្រាកំណើន ផសស ពិត នៅសិង្ហបុរី កើន ០,៥ឯកតាភាគរយ និងនៅថៃ កើន ១,១ឯកតាភាគរយធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅចិន មានអត្រាមធ្យម ៧,០% ប៉ុន្តែនៅហុងកុង វាធ្លាក់ចុះមកត្រឹម ២,១% ហើយនៅកូរ៉េខាងត្បូង ធ្លាក់មក ២,៤%។ កំណើន ផសស ក្នុងពេល ១២ខែ នៅតៃវ៉ាន់ មានអត្រា ៣,៤% ធៀបនឹង ៣,១% កាលពីមួយឆ្នាំមុន។

អត្រាកំណើនពិតនៅតំបន់អឺរ៉ូ កើនដល់ ១,០%។ អត្រានេះធ្លាក់ចុះមកត្រឹម ០,៩% នៅជប៉ុន ទោះបីប្រាក់យេនបានធ្លាក់ថ្លៃ ដែលនាំឲ្យមានកំណើនការនាំចេញ និង កំណើន ផសស ០,១ឯកតាភាគរយក្តី។ សហរដ្ឋអាមេរិក សម្រេចបានកំណើនខ្លាំងដល់ ២,៧% ឬ ខ្ពស់ជាងមួយឆ្នាំមុន ០,៤ឯកតាភាគរយ។ ការនាំចេញ និង ចំណាយរដ្ឋាភិបាលមូលដ្ឋាន និង ចំណាយរដ្ឋ ក៏បានរួមចំណែកជំរុញកំណើន ផសស ដែរ។

## អតិផរណា

នៅត្រីមាសទី១ អតិផរណាក្នុងប្រទេសជឿនលឿន និង ប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង មានតួលេខត្រឹមមួយខ្ទង់។ អតិផរណា ធ្លាក់មកត្រឹម ១,០% នៅកម្ពុជា ធៀបនឹង ២,២% កាលពីត្រីមាសមុន។ នៅត្រីមាសទី១ អតិផរណាប្រចាំឆ្នាំ មានអត្រា ៦,៦% នៅឥណ្ឌូនេស៊ី និង ០,៧% នៅម៉ាឡេស៊ី។ សិង្ហបុរីបានជួបបរិត្តផរណា ក្នុងពីរត្រីមាសចុងក្រោយ ដោយសារមានការធ្លាក់ថ្លៃសម្លៀកបំពាក់ ស្បែកជើង និងកន្លែងស្នាក់នៅ។ អតិផរណានៅវៀតណាម មានត្រឹម ០,៧% ដែលជាអត្រាទាបបំផុតក្នុងរយៈពេល ៩ឆ្នាំកន្លងទៅ។ ការថយចុះនេះ បណ្តាលមកពីការធ្លាក់ចុះថ្លៃប្រេងនៅលើពិភពលោក។ អតិផរណាប្រចាំឆ្នាំ ធ្លាក់ចុះមកត្រឹម ១,២% នៅចិន ៤,៤% នៅហុងកុង និង ០,៦% នៅកូរ៉េខាងត្បូង។ អតិផរណានៅតៃវ៉ាន់ កើនដល់ ២,៩% ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេល ៧ឆ្នាំកន្លងទៅ។ អតិផរណានៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក ធ្លាក់ចុះ ០,៣% និង ០,៤% រៀងគ្នា។ អតិផរណាប្រចាំឆ្នាំនៅជប៉ុន មានកម្រិតទាបដដែល ត្រឹម ២,៣% ឬធ្លាក់ចុះ ០,៣ឯកតាភាគរយ បើធៀបនឹងត្រីមាសមុន។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១៥ ទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោកបានធ្លាក់ថ្លៃ ធៀបនឹងត្រីមាសមុន។ ប្រេងឆាធ្លាក់ថ្លៃ ១២,២% មកត្រឹម ៦២៧,៩ដុល្លារ/តោន កៅស៊ូធ្លាក់ថ្លៃ ៥,៧% មកត្រឹម ១៤៥០,២ដុល្លារ/តោន ហើយអង្ករធ្លាក់ថ្លៃ ១,០% មកត្រឹម ៤២៦,០ដុល្លារ/តោន។ សណ្តែកសៀង ធ្លាក់ថ្លៃ ១៧,២% មកត្រឹម ៣៦៣,៩ដុល្លារ/តោន ហើយប្រេងឆៅ ធ្លាក់ថ្លៃ ៣០,៧% មកត្រឹម ៥០,៩ដុល្លារ/ធុង។ សាំងធ្លាក់ថ្លៃ ១៧,០% មកត្រឹម ០,៤០ដុល្លារ/លីត្រ ហើយ ម៉ាស៊ូតធ្លាក់ថ្លៃ ២២,៤% មកត្រឹម ០,៤៥ដុល្លារ/លីត្រ។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ុ បុប្ផារ័ត្ន និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 5.1 | 5.0 | 5.4 | 4.7 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.2 | 6.4 | 5.6 | 5.8 | 5.6 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 5.1 | 2.4 | 2.4 | 2.1 | 2.6 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 3.1 | 0.3 | 0.6 | 2.2 | 3.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.4 | 6.2 | 5.2 | 5.4 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.1 | 7.5 | 7.3 | 7.3 | 7.1 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 | 2.1 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 4.1 | 3.5 | 3.2 | 2.8 | 2.4 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.1 | 3.7 | 3.8 | 3.3 | 3.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.9 | 0.7 | 0.3 | 0.9 | 1.0 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 3.1 | -0.1 | -1.2 | 0.5 | -0.9 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.3 | 2.6 | 2.3 | 2.4 | 2.7 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 3.0 | 4.5 | 4.9 | 4.0 | 2.2 | 1.0 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 7.7 | 7.1 | 4.3 | 6.5 | 6.6 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.5 | 3.3 | 3.0 | 2.8 | 0.7 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | 2.3 | 0.9 | -0.1 | -0.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 2.0 | 2.5 | 2.0 | 1.1 | -0.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 4.7 | 4.5 | 5.4 | 0.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.1 | 2.2 | 2.0 | 1.5 | 1.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.1 | 3.6 | 4.9 | 5.0 | 4.4 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.1 | 1.6 | 1.4 | 1.0 | 0.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.1 | 1.6 | 1.5 | 1.6 | 2.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.6 | 0.6 | 0.4 | 0.2 | -0.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 1.5 | 3.6 | 3.4 | 2.6 | 2.3 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.4 | 2.1 | 1.8 | 1.3 | -0.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 5369.6 | 3993.8 | 4026.9 | 4059.5 | 4070.1 | 4042.2 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419 | 9699 | 10,413.8 | 9089.9 | 4374.0 | 9363.0 | 13892.2 | 11,765.8 | 11,615.3 | 11,775.7 | 12,244.1 | 12,809.9 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 4.2 | 3.3 | 3.2 | 3.2 | 3.4 | 3.6 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.51 | 1.42 | 1.5 | 1.4 | 1.3 | 1.2 | 1.7 | 1.3 | 1.3 | 1.3 | 1.3 | 1.4 |
| ថៃ (បាត) | 32.22 | 33.36 | 34.3 | 31.7 | 30.5 | 31.1 | 41.0 | 32.6 | 32.4 | 32.1 | 32.7 | 32.6 |
| វៀតណាម (ដុង) | 16,030.0 | 16,382 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 27,987.1 | 21,093.8 | 20,923.2 | 21,221.9 | 21,314.0 | 21,372.9 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.03 | 6.94 | 6.8 | 6.8 | 6.5 | 6.3 | 8.2 | 6.1 | 6.2 | 6.2 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 10.3 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1460.0 | 1069.7 | 1028.9 | 1027.5 | 1088.4 | 1101.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 39.6 | 30.3 | 30.1 | 30.0 | 30.9 | 31.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 1.0 | 0.7 | 0.7 | 0.8 | 0.8 | 0.9 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 130.2 | 102.8 | 102.1 | 104.0 | 114.6 | 119.2 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - USA (USD/តោន) | 163.7 | 223.1 | 165.5 | 185.9 | 291.7 | 298.4 | 259.4 | 209.9 | 214.0 | 174.1 | 173.5 | 174.2 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 780.3 | 948.5 | 682.8 | 900.8 | 1125.4 | 999.3 | 856.9 | 911.3 | 887.1 | 772.0 | 715.3 | 627.9 |
| កៅស៊ូ SMR 5 (USD/តោន) | 0.0 | 1431.6 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 2034.7 | 1777.6 | 1672.1 | 1538.1 | 1450.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 450.7 | 411.7 | 447.0 | 430.3 | 426.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 384.0 | 522.8 | 436.9 | 449.8 | 540.7 | 591.4 | 538.4 | 552.3 | 517.8 | 457.3 | 439.7 | 363.9 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 66.8 | 99.4 | 57.7 | 76.8 | 106.2 | 109.5 | 105.9 | 104.7 | 105.9 | 100.8 | 73.4 | 50.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 52.2 | 68.1 | 40.8 | 53.3 | 71.9 | 74.6 | 71.2 | 70.1 | 74.1 | 70.0 | 48.3 | 40.1 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 76.2 | 43.0 | 56.1 | 75.7 | 80.7 | 78.4 | 77.5 | 77.1 | 73.7 | 57.5 | 44.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើន ១៨១៦,៨% ធៀបត្រីមាសមុន និង ៥៧៣,០% ធៀបមួយឆ្នាំមុន ដល់ ២៨៧៣,២លានដុល្លារ។ វិនិយោគក្នុងវិស័យកាត់ដេរ មានចំណែក ១៨,៦% នៃគម្រោងសរុប ដោយបានកើនឡើង ១១០,៨% ធៀបត្រីមាសមុន ដល់ ៦៣,៩លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម កើនពីកម្រិតសូន្យ ដល់ ២៥,៨លានដុល្លារ។ វិនិយោគក្នុងវិស័យសេវាកម្ម មានចំណែក ៨៧% ក្នុងអនុមតិគម្រោងសរុប ហើយកំណើនដ៏ធំនេះបានមកពីការរួមចំណែកនៃអនុវិស័យទេសចរណ៍ និងសណ្ឋាគារ ៦០,៦លានដុល្លារ, អនុវិស័យទូរគមនាគមន៍ ២៧០,១លានដុល្លារ និងអនុវិស័យផ្សេងទៀត ២១៧១,២លានដុល្លារ។

នៅត្រីមាសទី១ ឆ្នាំ២០១៥ ភ្ញៀវទេសចរមកដល់កម្ពុជាសរុប កើន ៥,៤% ធៀបត្រីមាសមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១៣,៥% ប៉ុន្តែភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២,៥%។ ក្នុងរយៈពេល ៥ត្រីមាសជាប់ៗគ្នាកន្លងទៅ ចំនួនភ្ញៀវទេសចរមកកម្ពុជា កើនក្នុងអត្រាលេខមួយខ្ទង់។

ការនាំចេញសរុប កើន ១,៥% ធៀបនឹងត្រីមាសមុន និង ៩,៨% ធៀបនឹងឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៣,៨% ដល់ ១៥៤៨,៨លានដុល្លារ ធៀបនឹង ១៤៩២,៦លានដុល្លារ កាលពីត្រីមាសមុន។ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប នៅតែជាទីផ្សារចម្បងសម្រាប់ផលិតផលសម្លៀកបំពាក់ ដោយមានចំណែក ៣២% និង ៤០% រៀងគ្នា។ ទោះយ៉ាងណាក្តី ការនាំចេញទៅសហភាពអឺរ៉ុប រួមចុះ ៣,៣% បើធៀបនឹងត្រីមាសមុន។ ការនាំចេញសម្លៀកបំពាក់ទៅប្រទេសសមាជិកអាស៊ាន កើន ១៤,១% និងទៅជប៉ុន កើន ៣៦,១% ប៉ុន្តែការនាំចេញទៅប្រទេសទាំងនេះ រួមចំណែកត្រឹមតែ ១,៦% និង ៧,៨% រៀងគ្នាក្នុងការនាំចេញសរុបប៉ុណ្ណោះ។

នៅត្រីមាសទី១ ដដែល ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះ ៩,៦% ធៀបត្រីមាសមុន និង ១០% ធៀបឆ្នាំមុន។ អង្ករ និងកៅស៊ូ ជាផលិតផលកសិកម្មចម្បងគេ ដោយមានចំណែក ២៨% និង ៦០% រៀងគ្នាក្នុងផលិតផលកសិកម្មនាំចេញសរុប។ ធៀបនឹងត្រីមាសមុន ការនាំចេញកៅស៊ូ ធ្លាក់ចុះ ១២,២% មកត្រឹម ៤១,៧លានដុល្លារ ហើយការនាំចេញត្រី ធ្លាក់ចុះ ២៨,៦% រីឯការនាំចេញផលិតផលកសិកម្មផ្សេងទៀត ធ្លាក់ចុះ ៨១,៩% ប៉ុន្តែការនាំចេញអង្ករ កើន ៩,០% ដល់ ៨៩,៥លានដុល្លារ ហើយការនាំចេញឈើ កើន ៧០,១% ដល់ ១៣,៩លានដុល្លារ។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

នៅត្រីមាសទី១ ការនាំចូលសរុបធ្លាក់ចុះ ៣,២% ធៀបត្រីមាសមុន ប៉ុន្តែកើន ២១,៤% ធៀបឆ្នាំមុន ដល់ ២៧១៧,៣លានដុល្លារ។ ការនាំចូលសាំងធ្លាក់ចុះ ៦,៣% រីឯការនាំចូលម៉ាស៊ូតកើន ១១,៩% ហើយការនាំចូលសម្ភារសំណង់កើន ៨,៥% ធៀបនឹងត្រីមាសមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ចំណូលរដ្ឋាភិបាលសរុប ធ្លាក់ចុះ ១០,៧% ធៀបត្រីមាសមុន មកត្រឹម ២៦៣៣,៥៣ាន់លានរៀល ក្នុងនោះ ចំណូលចរន្ត ធ្លាក់ចុះ ៦,៤% មកត្រឹម ២៦២៣,៧ពាន់លានរៀល។ ចំណូលពន្ធ កើន ២,៥% ដល់ ២៤១៦,៨ពាន់លានរៀល ដោយរួមចំណែកបាន ៩១,៨% ក្នុងចំណូលរដ្ឋាភិបាលសរុប។ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៥៣,៥% មកត្រឹម ២០៦,៩ពាន់លានរៀល។ នៅត្រីមាសដដែល ចំណាយសរុប ធ្លាក់ចុះ ៥៦,២% ធៀបត្រីមាសមុន មកត្រឹម ១៩៥៨,០ពាន់លានរៀល ដោយសារការថយចុះ ៦៦,៦% នៃចំណាយមូលធន និង ៥០,៥% នៃចំណាយចរន្ត។ ចំណាយមូលធន ធ្លាក់ចុះមកត្រឹម ៥២៩,៤ ពាន់លានរៀល ហើយចំណាយចរន្ត ធ្លាក់ចុះមកត្រឹម ១៤២៨,៧ ពាន់លានរៀល ដោយសារការធ្លាក់ចុះនៃចំណាយលើបៀវត្សរ៍ ឧបត្ថម្ភធននិងជំនួយសង្គម និង ចំណាយចរន្តផ្សេងទៀត។

## អតិផរណា និងអត្រាប្តូរប្រាក់

ក្នុងរយៈពេលមួយឆ្នាំរហូតដល់ត្រីមាសទី១ ឆ្នាំ២០១៥ ថ្លៃទំនិញសរុប កើន ១,០% ធៀបនឹងកំណើន ៤,៦% ក្នុងរយៈពេលមួយឆ្នាំរហូតដល់ត្រីមាសទី១ ឆ្នាំ២០១៤។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៤,២% រីឯថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ១០,៩%។ ប្រាក់រៀល ឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ, ០,២% ទល់នឹងប្រាក់បាតថៃ និង ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ មាសឡើងថ្លៃ ៧,០% ធៀបនឹងត្រីមាសមុន ដល់ ១៥០.៩ដុល្លារ/ជី រីឯម៉ាស៊ូត និងសាំង ធ្លាក់ថ្លៃ ១២,០% និង ១៣,៦% រៀងគ្នា។

## ស្ថានភាពក្រីក្រ

នៅខែឧសភា ២០១៥ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និងអ្នកស៊ីឈ្នួលធ្វើស្រែ បានធ្លាក់ចុះ បើធៀបនឹងខែឧសភា ២០១៤។ អង្កេតក្នុងខែឧសភានេះបង្ហាញថា ពលករ ៤ក្រុម រកប្រាក់ចំណូលបានតិចជាងកាលពី អង្កេតក្នុងខែកុម្ភៈ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកជាក់ស៊ីក្លូ ធ្លាក់ចុះ ៣,៧% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១២.៤២៧រៀល/ថ្ងៃ ដោយសារជាសំខាន់ អតិថិជនមានចំនួនតិចជាងមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នា សុទ្ធតែមកពីតាមខេត្តនៅក្បែររាជធានីភ្នំពេញ ជាពិសេសខេត្តព្រៃវែង (៥២%)។ អ្នកជាក់ស៊ីក្លូស្ទើរតែគ្រប់គ្នាជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយ ៧២% នៃអ្នកឆ្លើយសម្ភាសន៍ប្រាប់ថា ចំណូលរបស់ខ្លួនមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារទេ។ ចំណាយប្រចាំថ្ងៃរបស់អ្នកជាក់ស៊ីក្លូ ស្រូបអស់ ៧៨% នៃប្រាក់ចំណូលសរុបរបស់គាត់ ហើយភាគច្រើនទៅលើម្ហូបអាហារសម្រាប់ខ្លួនគាត់។ គ្រួសារអ្នកជាក់ស៊ីក្លូ ៦៨% ត្រូវស៊ីឈ្នួលធ្វើស្រែដើម្បីរកចំណូលបន្ថែម។

ប្រាក់ចំណូលរបស់អ្នកលីសែង ធ្លាក់ចុះ ៦,០% ធៀបអង្កេតលើកមុន មកត្រឹម ១៥.៧៨២រៀល/ថ្ងៃ ហើយពួកគេ ៨០% ប្រាប់ថា វាបណ្តាលមកពីកង្វះការងារ និងកំណើនចំនួនអ្នកប្រកបរបរនេះ។ អ្នកលីសែង ៩២% ត្រូវជួលកន្លែងស្នាក់នៅក្នុងក្រុងភ្នំពេញ ដោយមានគ្នាជាមធ្យម ៦នាក់ក្នុងមួយកន្លែង។ ពួកគេចំណាយប្រាក់អស់ ១០០០រៀល/ថ្ងៃ លើថ្លៃឈ្នួលកន្លែងស្នាក់នៅ។ នៅក្នុងចំណាយសរុបប្រចាំថ្ងៃរបស់ពួកគេ ចំណាយលើស្បៀងអាហារមានចំណែក ៨៩%។

នៅខែឧសភា ចំណូលរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៧,៣% មកត្រឹម ១៥.៤៥៣រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៧០% ប្រាប់ថា មានមនុស្សកាន់តែច្រើនមកចាប់យកការងារនេះ ប៉ុន្តែការងារមានតិចជាងមុន។ ជាមធ្យម កម្មករធ្វើការ ៨ម៉ោង/ថ្ងៃ។ ពួកគេ ៧៨% មករស់នៅរាជធានីភ្នំពេញតែម្នាក់ឯង ហើយប្រាក់ចំណូលរកបាន អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

ប្រាក់ចំណូលរបស់កម្មករមានជំនាញ កើន ១៧% ដល់ ១៩.៩១៨រៀល/ថ្ងៃ។ កម្មករ ៥៥% មករស់នៅភ្នំពេញជាមួយគ្រួសារ។ ពួកគេភាគច្រើនស្នាក់នៅកន្លែងការដ្ឋាន។ ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់គ្រួសារទេ ហេតុនេះសមាជិកគ្រួសារនៅឯស្រុក ត្រូវរកចំណូលបន្ថែមដោយចិញ្ចឹមសត្វ ឬស៊ីឈ្នួលធ្វើស្រែឲ្យគេ។

ប្រាក់ចំណូលរបស់អ្នកលក់បន្លែ កើន ២១% ធៀបនឹងខែកុម្ភៈ ដល់ ១៨.១៧១រៀល/ថ្ងៃ។ ពួកគេភាគច្រើនមកពីខេត្តកណ្តាល (៣៣%)។ អ្នកលក់បន្លែ ៤៥% ធ្វើដំណើរទៅមកផ្ទះប្រចាំថ្ងៃ រីឯអ្នកផ្សេងទៀតបានជួលផ្ទះគេនៅ ឬស្នាក់នៅជាមួយសាច់ញាតិនៅភ្នំពេញ។ អ្នកឆ្លើយសម្ភាសន៍ ៧៥% ប្រាប់ថា ចំណូលរបស់ខ្លួន មិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់គ្រួសារ ឬពង្រីកអាជីវកម្មទេ ដោយមាន ៣៨% ត្រូវខ្ចីបុលគេដើម្បីធ្វើអាជីវកម្ម និងដោះស្រាយចំណាយទ្រទ្រង់ជីវភាព។

អ្នករើសអេតចាយ មានចំណូលកើនដល់ ១៤.១៦៩រៀល/ថ្ងៃ ឬអត្រាកំណើនប្រាក់ចំណូលខ្ពស់ជាងគេ គឺ ៣៣%។ អ្នករើសអេតចាយ ៧៨% មកភ្នំពេញជាមួយគ្រួសារ។ ពួកគេពឹងផ្អែកជាសំខាន់លើការងារនេះ ប៉ុន្តែ ៧៥% ប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួនមិនគ្រប់គ្រាន់សម្រាប់ការចាយវាយទេ។ ហេតុនេះ អ្នករើសអេតចាយ ៧៥% ត្រូវខ្ចីប្រាក់គេដើម្បីដោះស្រាយចំណាយប្រចាំថ្ងៃ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ១,១% ធៀបនឹងអង្កេតលើកមុន ដល់ ១៤.៨០៣រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ១២០នាក់ កម្រិតសិក្សាដែលខ្ពស់ជាងគេ គឺ ត្រឹមថ្នាក់ទី៣។ ម្យ៉ាងទៀត មានកម្មករតែ ២៩% ប៉ុណ្ណោះ ដែលបានចូលរៀនវគ្គបណ្តុះបណ្តាលមុនពេលចូលធ្វើការ។ ការងារចម្បងរបស់ពួកគេគឺ ដេរ និងប៉ាក់សាមញ្ញៗ។ ពួកគេធ្វើការ ៥៨ម៉ោង/សប្តាហ៍ (៦ថ្ងៃ/សប្តាហ៍) រួមទាំងការងារបន្ថែមម៉ោងផង។ កម្មករ ៤០% អាចសន្សំប្រាក់សម្រាប់អនុវត្តផែនការការងារទៅថ្ងៃអនាគតរបស់ខ្លួន រីឯអ្នកផ្សេងទៀតមិនអាចទ្រទ្រង់ជីវភាពគ្រួសារដែលពឹងផ្អែកជាចម្បងលើពួកគេឡើយ។

# តាមដានសេដ្ឋកិច្ច - សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១៥*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92 | 615.0 | 530.7 | 725 | 531.6 | 930.5 | 28.9 | 27.6 | 0.0 | 0.0 | 25.8 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257 | 179.0 | 239.3 | 434.3 | 149.9 | 342.8 |
| *កាត់ដេរ* | 170.7 | 142.8 | 90.1 | 122.8 | 393.9 | 497 | 324.1 | 109.3 | 172.4 | 81.6 | 30.3 | 63.9 |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 219.1 | 114.4 | 289.1 | 0.0 | 2504.6 |
| *សណ្ឋាគារ និងទេសចរណ៍* | 1048.3 | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106 | 163.3 | 15.4 | 268.1 | 0.0 | 60.6 |
| សរុប | 2587.2 | 10570.9 | 5865.5 | 2271.7 | 7010.42 | 2278.0 | 4328 | 426.9 | 302.2 | 625.8 | 149.9 | 2873.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -75.8 | -29.2 | 64.1 | -76.0 | 1816.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -32.0 | 308.6 | -44.5 | -61.3 | 209 | -67.5 | 90.1 | 95.1 | -81.8 | 142.7 | -91.5 | 573.0 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 376.3 | 376.2 | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 |
| ផ្សេងៗ | 259.5 | 740.9 | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | - | 30.3 | 38.5 | 76.9 | 435.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1280.2 | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 699.0 | 438.2 | 497.5 | 638.8 | 725.1 |
| តាមផ្លូវគោក និងទឹក | 740.5 | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 569.0 | 495.2 | 501.2 | 663.9 | 647.6 |
| សរុប | 2020.7 | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 1268.0 | 933.4 | 998.7 | 1302.7 | 1372.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 10.0 | -26.4 | 7.0 | 30.4 | 5.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 18.9 | 5.0 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 8.0 | 1.4 | 3.5 | 13.0 | 8.3 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១៥ *

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 1976.5 | 1859.8 | 2132.5 | 2137.1 | 2170.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2938.9 | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 1464.0 | 1379.2 | 1624.7 | 1492.6 | 1548.8 |
| - *សហរដ្ឋអាមេរិក* | 1956.5 | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 531.1 | 452.5 | 511.2 | 468.8 | 491.08 |
| - *សហភាពអឺរ៉ុប* | 654.3 | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 532.7 | 558.5 | 673.8 | 638.7 | 617.3 |
| - *អាស៊ាន* | 3.2 | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 21.9 | 19.3 | 20.5 | 21.7 | 24.8 |
| - *ជប៉ុន* | 28.5 | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 278.7 | 101.4 | 74.9 | 117.6 | 89.2 | 121.4 |
| - *ប្រទេសផ្សេងៗ* | 296.4 | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 277.0 | 273.9 | 301.6 | 274.2 | 294.2 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 167.0 | 157.3 | 133.7 | 166.4 | 150.3 |
| - *កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 31.7 | 40.0 | 34.8 | 47.5 | 41.7 |
| - *ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 55.9 | 48.4 | 19.6 | 8.2 | 13.9 |
| - *ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 1.2 | 0.3 | 0.2 | 0.1 | 0.2 | 0.2 |
| - *អង្ករ* | 1.5 | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 57.9 | 52.8 | 55.8 | 82.0 | 89.5 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 21.2 | 16.0 | 23.5 | 28.5 | 5.2 |
| ផ្សេងៗ | 55.8 | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 345.5 | 323.3 | 373.0 | 478.2 | 471.0 |
| ការនាំចូលសរុប ក្នុងនេះ៖ | 3770 | 4272 | 4331.5 | 5190.6 | 6375.9 | 8593.3 | 8639.4 | 2238.2 | 2454.4 | 2794.8 | 2807.9 | 2717.3 |
| សាំង | 73.7 | 84.9 | 91.13 | 108.6 | 294.4 | 308.0 | 306.4 | 77.4 | 83.2 | 80.2 | 93.9 | 34.5 |
| ម៉ាស៊ូត | 133.7 | 119.5 | 180.67 | 203.8 | 447 | 559.5 | 569.1 | 148.5 | 142.5 | 163.4 | 147.9 | 45.1 |
| សម្ភារសំណង់ | 44.3 | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 80.8 | 27.8 | 29.2 | 29.0 | 31.6 | 12.4 |
| ផ្សេងៗ | 3518.5 | 4011.8 | 4010 | 4820.6 | 5586.4 | 7659.1 | 7682.6 | 1984.5 | 2199.5 | 2522.2 | 2534 | 835.2 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | | -261.7 | -589.5 | -662.3 | -670.8 | -547.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | | 9.8 | -5.8 | 17.8 | -8.1 | 3.8 |
| ការនាំចេញសរុប | - | - | - | - | - | - | | 8.9 | -5.9 | 14.7 | 0.2 | 1.5 |
| ការនាំចូលសរុប | - | - | - | - | - | - | | 5.1 | 9.4 | 14.1 | 0.5 | -3.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 32.1 | 17.7 | | 19.5 | 9.6 | 3.6 | 11.9 | 5.8 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 35.8 | 23.9 | | 25.3 | 14.8 | 8.3 | 17.7 | 9.8 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 22.8 | 16.8 | | 2.1 | 10.8 | 35.7 | 31.8 | 21.4 |

* Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៧-១៥ (ពាន់លានរៀល)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 1146.1 | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 2220.5 | 2793.7 | 2580.6 | 2948.6 | 2633.5 |
| ចំណូលចរន្ត | 1141.6 | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 2219.2 | 2765.2 | 2571.4 | 2803.6 | 2623.7 |
| ចំណូលពន្ធ | 965.2 | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 1988.7 | 2383.1 | 2264.6 | 2358.8 | 2416.8 |
| ពន្ធក្នុងស្រុក | 661.8 | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 1593.6 | 1943.2 | 1798.0 | 1891.6 | 2002.8 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 303.5 | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 449.0 | 439.9 | 466.5 | 467.2 | 414.0 |
| ចំណូលមិនមែនពន្ធ | 176.4 | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 176.6 | 382.1 | 306.9 | 444.8 | 206.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 13.6 | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 11.1 | 40.8 | 21.2 | 15.4 | 3.0 |
| លក់ទំនិញ និងសេវា | 124.3 | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 160.3 | 197.5 | 212.9 | 300.5 | 189.2 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 38.5 | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 5.2 | 143.7 | 72.7 | 128.9 | 14.7 |
| ចំណូលជាមូលធន | 4.5 | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 1.3 | 28.5 | 9.2 | 145.0 | 9.8 |
| ចំណាយសរុប | 1689.7 | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 2618.8 | 2867.2 | 3349.0 | 4471.4 | 1958.1 |
| ចំណាយជាមូលធន | 807.4 | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 1187.1 | 1395.9 | 1421.7 | 1586.0 | 529.4 |
| ចំណាយចរន្ត | 882.3 | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 1431.7 | 1471.4 | 1927.3 | 2885.4 | 1428.7 |
| បៀវត្សរ៍ | 362.6 | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 860.0 | 931.0 | 918.4 | 1046.1 | 935.1 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 194.2 | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 213.1 | 259.6 | 434.8 | 719.5 | 194.3 |
| ចំណាយចរន្តផ្សេងទៀត | 325.5 | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 358.6 | 280.8 | 574.1 | 1119.9 | 299.3 |
| សមតុល្យជាទូទៅ | -543.6 | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -398.4 | -73.5 | -768.5 | -522.8 | 675.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 741.5 | 2055.1 | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 977.9 | 1123.9 | 1,012.5 | 857.9 | 232.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -185.8 | -127 | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -915.0 | -172.9 | -279.3 | -61.4 | -1,248.7 |

Source: Ministry of Economy and Finance website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 3.9 | 4.6 | 4.8 | 4.0 | 2.1 | 1.0 |
| - អាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 4.9 | 5.7 | 5.3 | 5.1 | 3.4 | 4.2 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -1.0 | -1.1 | 0.5 | -0.2 | -3.3 | -10.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 4036.2 | 3993.8 | 4026.9 | 4059.5 | 4064.7 | 4042.2 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 124.9 | 123.0 | 124.8 | 127.1 | 124.6 | 124.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.1 | 19.1 | 19.2 | 19.2 | 19.1 | 19.0 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 83.2 | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 152.3 | 156.6 | 155.9 | 155.5 | 141.1 | 150.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4971.2 | 5006.7 | 5047.6 | 4382.8 | 3823.4 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5171.5 | 5200.0 | 5348.6 | 4613.0 | 3986.2 |

Sources: National Institute of Statistics, National Bank of Cambodia and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៧-១៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 23,344.4 | 26,235.8 | 26,817.8 | 26,699.7 | 26,823 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 576.0 | 15,13.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 11,817.4 | 12,024.4 | 13,950.5 | 15,859.8 | 16,863.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 | -5064 |
| ឥណទានដល់ផ្នែកឯកជន | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 28,584.5 | 30,621.3 | 33,226.4 | 36,244.6 | 37,759.4 |
| រូបិយវត្ថុទូទៅ M2 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 35,161.8 | 38,259.9 | 40,768.3 | 42,559.5 | 43,685.2 |
| រូបិយវត្ថុ M1 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 | 6628.0 |
| រូបិយវត្ថុផ្សេងៗ | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 27,890.2 | 29,785.7 | 33,028.5 | 35,185.2 | 36,251.1 | 37,058.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 15.4 | 20.8 | 38.9 | 29.9 | 24.2 |
| រូបិយវត្ថុ M1 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 19.5 | 14.1 | 18.3 | 29.3 | 23.3 |
| រូបិយវត្ថុផ្សេងៗ | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 14.6 | 22.0 | 42.8 | 30.0 | 24.4 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2011 | 2012 | 2013 | 2014 | | | | 2015 | | 2014 | 2015 | |
| | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 9532 | 10,303 | 10,438 | 10,832 | 10,764 | 9867 | 11,634 | 12,950 | 12,467 | 7.8 | 19.6 | 26.4 |
| អ្នកលីសែង | 10,785 | 12,143 | 13,247 | 12,141 | 12,568 | 13,399 | 16,188 | 16,798 | 15,782 | 22.2 | 38.4 | 17.8 |
| អ្នកលក់បន្លែតូចតាច | 8337 | 10,771 | 11,366 | 12,294 | 13,581 | 15,372 | 17,735 | 15,007 | 18,171 | 43.1 | 22.1 | 22.1 |
| អ្នករើសអេតចាយ | 8388 | 8680 | 9819 | 9593 | 9214 | 8337 | 9548 | 10,627 | 14,169 | -1.4 | 10.8 | 10.8 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5986 | 6111 | 6697 | 7449 | 6696 | 7565 | 9435 | 8,466 | 8,742 | 40.0 | 13.7 | 15.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5695 | 6151 | 6599 | 8932 | 5836 | 8795 | 6781 | 8,303 | 8,063 | 6.6 | -7.0 | -8.3 |
| កម្មកររោងចក្រកាត់ដេរ | 8409 | 8932 | 10,161 | 9548 | 11,412 | 11,388 | 12,092 | 14,644 | 14,803 | 16.3 | 53.4 | 29.7 |
| អ្នករត់ម៉ូតូឌុប | 11,568 | 12,930 | 13,450 | 13,227 | 13,401 | 12,656 | 14,259 | 14,549 | 14,692 | 8.6 | 10 | 16.1 |
| កម្មករសំណង់គ្មានជំនាញ | 10,307 | 11,078 | 13,184 | 15,162 | 15,316 | 15,401 | 15,436 | 16,678 | 15,453 | 15.4 | 10 | 0.3 |
| កម្មករសំណង់មានជំនាញ | 13,159 | 13,743 | 15,442 | 15,163 | 15,765 | 20,420 | 18,302 | 17,050 | 19,918 | 10.4 | 12.4 | -2.5 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000.
Source: CDRI

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ**...

ព្រឹត្តិការណ៍នេះបានប្រារព្ធឡើង នៅថ្ងៃទី ២៦ មិថុនា ដើម្បីឲ្យបានស្របពេលគ្នាជាមួយទស្សនកិច្ចនៃ គណៈប្រតិភូជាន់ខ្ពស់នៃ CPAPD ដឹកនាំដោយ ឯកឧត្តម Han Qide អនុប្រធានគណៈកម្មាធិការជាតិ នៃសន្និសីទពិគ្រោះយោបល់ ផ្នែកនយោបាយ នៃសាធារណរដ្ឋប្រជាមានិតចិន និង ប្រធាននៃ CPAPD។ សុន្ទរកថាគន្លឹះត្រូវបានធ្វើឡើងដោយ ឯកឧត្តម Han Qide និង ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

កិច្ចសន្ទនា ដែលមានការចូលរួមតាមការអញ្ជើញពីសំណាក់អ្នកតំណាងជាន់ខ្ពស់ប្រហែល ១០០នាក់ មកពី សហគមន៍ស្រាវជ្រាវផ្នែកគោលនយោបាយ វិស័យអប់រំ វិស័យឯកជន សមាគមយុវជន និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត បានផ្ដល់ជាវេទិកាដ៏វិសេសសម្រាប់ការពិភាក្សាពី ឱកាស និងបញ្ហាប្រឈម ផុសចេញពីការពង្រីកពង្រឹងភាពជាដៃគូរបស់កម្ពុជាជាមួយប្រទេសចិន ទាំងជាលក្ខណៈទ្វេភាគី និងលក្ខណៈតំបន់ និងពីបែបបទដែលប្រទេសទាំងពីរអាចធ្វើការរួមគ្នា ដើម្បីបានផលប្រយោជន៍ទៅវិញទៅមក។

CDRI ក្នុងតួនាទីជាអ្នកសម្របសម្រួលនៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) នៃកម្ពុជា និងក្នុងនាម ក្រុមចំណាប់អារម្មណ៍ស្រាវជ្រាវ DRF អំពីកម្ពុជា និងតំបន់ជុំវិញ បានរៀបចំនូវកិច្ចប្រជុំតុមូលគោលនយោបាយមួយ ស្ដីពី "ការរៀបចំការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និងតទៅអនាគត"។ អ្នកតំណាងប្រហែល ៤០នាក់មកពីមជ្ឈដ្ឋានសិក្សាអប់រំ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលខាងវិស័យអប់រំនៅកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំតុមូល នៅថ្ងៃទី ៥ មិថុនា នេះ ដើម្បីពិភាក្សាពី បញ្ហាប្រឈម និងឱកាសល្អសម្រាប់ឧត្តមសិក្សានៅកម្ពុជា នៅក្នុងបរិបទនៃការធ្វើសមាហរណកម្មអាស៊ាន។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ក្រុមអ្នកស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សាចំនួន ៩ ក្នុងនោះមាន ១គម្រោង ត្រូវអនុវត្តរួមគ្នា ជាមួយក្រុមស្រាវជ្រាវផ្នែកសុខាភិបាល។ គម្រោងចំនួន ៣ ទទួលបានការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (Sida)។ របាយការណ៍សម្រាប់គម្រោងទី១ ស្ដីពី ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ បានចងក្រងរួចរាល់សម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ របាយការណ៍ព្រាងដំបូងសម្រាប់គម្រោងការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មកសិកម្ម កំពុងរង់ចាំយោបល់ត្រឡប់ពីអ្នកស្រាវជ្រាវក្នុងវិស័យដូចគ្នាដែលជួយពិនិត្យ។ សម្រាប់គម្រោងទី៣ ស្ដីពីផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង ខាងក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។

របាយការណ៍ព្រាងដំបូងសម្រាប់ការសិក្សាស្ដីពី ការវិភាគពីខ្សែចង្វាក់តម្លៃបន្លែម និងផលិតកម្មសត្វចិញ្ចឹម នៅក្នុងដំណាក់កាលទី២ នៃគម្រោង គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធដាំដុះផ្អែកលើដំណាំស្រូវនៅតំបន់មេគង្គកណ្ដាលដែលទទួលបានជំនួយទ្រទ្រង់ពី មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) កំពុងចងក្រងបង្ហើយ។ នៅខែមិថុនា ក្រុមស្រាវជ្រាវបានចាប់ផ្ដើមអនុវត្តគម្រោងថ្មីមួយស្ដីពីផលប៉ះពាល់នៃចំណាយសាធារណៈផ្នែកអប់រំ ទៅលើមូលធនមនុស្ស ភាពក្រីក្រ និងវិសមភាព៖ វិធីសាស្ត្រ CGE សម្រាប់កម្ពុជា។ ក្រុមស្រាវជ្រាវបានទទួលកិច្ចសន្យាមួយទៀត ដើម្បីអនុវត្តគម្រោងស្ដីពី ការវិភាគពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃគោលនយោបាយនាំចេញអង្ករបស់វៀតណាម សម្រាប់កម្ពុជាដែលទទួលបានជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈ គំនិតផ្ដួចផ្ដើមគោលនយោបាយសាធារណៈទន្លេមេគង្គក្រោម (LMPPI)។ ការស្រាវជ្រាវនេះគ្រោងចាប់ផ្ដើមនៅខែសីហា ២០១៥។ កិច្ចសន្យាសម្រាប់គម្រោងរយៈពេល ៤ឆ្នាំ (២០១៥-១៨) ស្ដីពី ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុងគម្រោង PADEE កម្ពុជា (គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា) ដែលទទួលបានមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវពី គោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) កំពុងរៀបចំឡើង ហើយសកម្មភាពស្រាវជ្រាវគ្រោងចាប់ផ្ដើមនៅចុងខែសីហា ឬដើមខែកញ្ញា។